ភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលគ្រប់គ្រងប្រមូលចំណូល ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ព្រមទាំងមន្ត្រីពាក់ព័ន្ធមួយចំនួន របស់អគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល និង ជាប្រធានអង្គប្រជុំ បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តមអគ្គនាយករង លោក-លោកស្រី មន្ត្រីរាជការពន្ធដារទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ និង សូមសម្តែងនូវការអរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈ។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ជាលទ្ធផល ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលបានចំណូលពន្ធ-អាករគ្រប់ប្រភេទ និង ធ្វើបែបបទសលាកបត្រ បង់ចូលថវិកាជាតិបានចំនួន ៤២១ ០៨៦,៣១ លានរៀល (ប្រមាណ ១០៥,២៧ លានដុល្លារ)។ ប្រសិនបើធៀបនឹងខែកុម្ភៈ ឆ្នាំ២០១៦ ឃើញថាការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧ កើនឡើងចំនួន ៣៨ ១៨៥,៧២ លានរៀល (ប្រមាណ ៩,៥៤ លានដុល្លារ) ឬស្មើនឹង អត្រាកំណើន ៩,៩៧%។

សម្រាប់រយៈពេលពីរខែ ឆ្នាំ២០១៧ ចំណូលពន្ធ-អាករគ្រប់ប្រភទប្រមូលបាន មានចំនួន ១ ៤០៦ ៣១៣,១២ លានរៀល (ប្រមាណជា ៣៥១,៥៨ លានដុល្លារ) ស្មើនឹង ២០,៤៩ %នៃគោលដៅកំណត់ដោយច្បាប់។

ប្រសិនបើប្រៀបធៀបនឹងខែកុម្ភៈ ឆ្នាំ២០១៦ ឃើញថា ចំណូលពន្ធតាមប្រភេទពន្ធ ដែលប្រមូលបានក្នុងខែកុម្ភៈ ឆ្នាំ២០១៧ មានការកើនឡើងស្ទើរគ្រប់ប្រភេទពន្ធ ជាពិសេសប្រភេទពន្ធ-អាករសំខាន់ៗមានជាអាទិ៍ ÷ ពន្ធលើប្រាក់ចំណូល កើនឡើង ១៦%, ពន្ធលើប្រាក់បៀវត្ស កើនឡើង ៥៣,១% និងអាករពិសេស កើនឡើង ៤៧,៩% ខណៈដែលអាករលើតម្លៃបន្ថែម មានការថយចុះ ២,២%។

បន្ថែមពីលើលទ្ធផលប្រមូលចំណូលប្រកបដោយជោគជ័យ អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងកែទម្រង់ ការគ្រប់គ្រងធនធានមនុស្ស ដោយបានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងវាយតម្លៃការងារ របស់មន្ត្រីរាជការពន្ធដារ ដែលប្រព័ន្ធនេះបានដាក់ឱ្យដំណើរការ កាលពីដើមឆ្នាំ២០១៧ កន្លងទៅ។ នេះអាចនិយាយបានថា អគ្គនាយកដ្ឋានពន្ធដារ គឺជាស្ថាប័នរដ្ឋតែមួយគត់ ដែលឈានមុខគេលើកិច្ចការកែទម្រង់ធនធានមនុស្ស។

ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តការប្រមូលចំណូលពន្ធបានគ្រប់តាមផែនការកំណត់ដោយច្បាប់ចំនួន ៦ ៨៦៣ ៣០០ លានរៀល (គិតជាដុល្លារ ១ ៧១៥,៨៣ លានដុល្លារ) ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំបាន ផ្តល់នូវអនុសាសន៍ណែនាំដល់អង្គភាពក្រោមឱវាទពន្ធដារ ឱ្យបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និង ប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយកែទម្រង់ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល និង កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានចេញនូវវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម ÷

- បន្តពង្រឹងយន្តការនៃការចុះបញ្ជីពន្ធដារ និង ប្រសិទ្ធភាពនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធ
- បន្តពង្រឹងប្រសិទ្ធភាព នៃការចាត់ចែងការដាក់លិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធ
- បន្តពង្រឹងការធ្វើសវនកម្មលើសហគ្រាស ដែលមានហានិភ័យខ្ពស់ ដែលព្យាយាមគេចវេះកាតព្វកិច្ចបង់ពន្ធតាមគ្រប់រូបភាព
- បន្តពង្រឹង និងបណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រីរាជការពន្ធដារ តាមរយៈការរៀបចំសិក្ខាសាលា និង វគ្គបណ្តុះបណ្តាលជំនាញបន្ថែម ទាំងក្នុងនិងក្រៅប្រទេស
- បន្តពង្រឹងអភិបាលកិច្ចល្អ និងកែប្រែផ្នត់គំនិតរបស់មន្ត្រីពន្ធដារ ឱ្យក្លាយជាអ្នកបម្រើសេវាសាធារណៈបានល្អ
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេសរៀបចំអភិវឌ្ឍកម្មវិធីគ្រប់គ្រងការប្រមូលពន្ធ គ្រប់ប្រភេទតាមបច្ចេកវិទ្យាព័ត៌មាន
- បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹង ការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ក្នុងចំណោមធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា។
- បន្តអប់រំណែនាំ ពង្រឹងការអនុវត្តច្បាប់ និង

សមត្ថភាព មន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ពង្រឹងអភិបាលកិច្ចល្អ របស់រដ្ឋបាលសារពើពន្ធ ជាពិសេសការកែប្រែផ្នត់គំនិត (Mindset) របស់មន្ត្រីរាជការពន្ធដារគ្រប់រូបឲ្យយកចិត្តទុកដាក់អនុវត្តការងារ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការវិជ្ជាជីវៈ និងស្មារតីតម្កល់ផលប្រយោជន៍ជាតិជាចម្បង ដោយចូលរួមអនុវត្តព្រមៗគ្នានូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅធ្វើយ៉ាងណាធានាបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ ដោយផ្អែកលើអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាលជម្ងឺ" ដែលបានដាក់ចេញដោយសម្តេចតេជោនាយករដ្ឋមន្ត្រី និងអភិក្រមការងារទាំងបួន ដែលបានដាក់ចេញដោយឯកឧត្តមទេសរដ្ឋមន្ត្រី។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំ ប្រឹងប្រែងប្រមូលចំណូលរហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ដែលនេះគឺជាជោគជ័យរួមរបស់អគ្គនាយកដ្ឋានពន្ធដារព្រោះថាប្រសិនបើមិនមានការចូលរួមពីគ្រប់អង្គភាពពាក់ព័ន្ធលទ្ធផលប្រមូលចំណូលពន្ធនេះនឹងមិនអាចសម្រេចទៅប្រកបដោយលទ្ធផលត្រចះត្រចង់បែបនេះបានឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ